## រឿងទី៥៖ ប្រាសាទបាបិល

**ខគម្ពីរ៖ លោកុប្បត្តិ១១៖៩**

ហេតុនេះហើយបានជាគេដាក់ឈ្មោះក្រុងនោះថា "បាបិល" ដ្បិតនៅទីនោះហើយដែលព្រះអម្ចាស់ បានបំបែកភាសារបស់មនុស្សលោកទាំងមូល ហើយព្រះអង្គធ្វើឲ្យមនុស្សបែកខ្ញែកគ្នាចេញពីទីនោះ ទៅពាសពេញលើផែនដីទាំងមូល។

ក្រោយទឹកជំនន់ធំនាន់ណូអេត្រូវបានបញ្ចប់ ពេលវេលាចេះតែកន្លងទៅ ថ្ងៃមួយក៏បានមកដល់។
កូនចៅរបស់ណូអេកាន់តែចម្រើនឡើងលើផែនដី ពួកគេរស់នៅជាមួយគ្នា និងនិយាយភាសាតែមួយដូចគ្នា។ ពួកគេទាំងនោះបានធ្វើដំណើរទៅទិសខាងកើត
ហើយបានមកជុំគ្នានៅវាលរាបមួយក្នុងស្រុកស៊ីណើរ តាំងទីលំនៅនៅទីនោះ។
មនុស្សជាច្រើនមករស់នៅជុំគ្នា ហើយចិត្តរបស់ពួកគេក៏កាន់តែធំឡើងៗ
មនុស្សកាន់តែមានប្រាជ្ញា ពួកគេកាន់តែមានចិត្តធំនៅចំពោះព្រះជាម្ចាស់។
ពួកគេគិតថា ពួកគេអាចខ្ពស់ខ្ពង់ដូចជាព្រះជាម្ចាស់បាន។
អស់មនុស្សដែលមានចិត្តលោភលន់កាន់តែខ្លាំងនោះ ពួកគេចាប់ផ្ដើមសាងសង់ប្រាសាទដ៏សែនខ្ពស់។
ពួកគេបានចាប់ផ្ដើមសាងសង់ប្រាសាទ ដែលខ្ពស់ដល់ផ្ទៃមេឃ។
មនុស្សម្នា សាងសង់ប្រាសាទដ៏ធំនិងខ្ពស់នេះ ដោយមិនទូលសួរព្រះជាម្ចាស់ថាទ្រង់សព្វព្រះទ័យឬអត់ឡើយ។
មនុស្សទាំងអស់ កាន់តែមានអំណួត ចិត្តកោតខ្លាចព្រះជាម្ចាស់ក៏កាន់តែបាត់អស់ទៅ។
ព្រះជាម្ចាស់បានទតឃើញមនុស្សទាំងអស់នោះកំពុងសាងសង់ប្រាសាទ។
ប៉ុន្តែ ក្នុងព្រះនេត្រទ្រង់ មិនឃើញថាវាជាកិច្ចការដ៏ល្អនោះទេ។
ដូច្នេះហើយ ព្រះជាម្ចាស់បានធ្វើឱ្យពួកគេនិយាយភាសាផ្សេងពីគ្នា។ ពេលនោះ មនុស្សទាំងអស់នោះ មិនយល់ពីភាសាដែលពួកគេនិយាយនោះទាល់តែសោះ។
ការយល់ច្រឡំកាន់តែខ្លាំងទៅៗ ក៏កើតមានជម្លោះ ធ្វើឱ្យពួកគេមិនអាចធ្វើការជាមួយគ្នាបានទៀត។
ហើយប្រាសាទដែលពួកគេចង់សាងសង់ឱ្យខ្ពស់រហូតដល់មេឃនោះក៏ត្រូវបានបញ្ឈប់ ម្នាក់ៗចាប់ផ្ដើមបែកខ្ញែកគ្នារស់នៅរៀងៗខ្លួន។ ក្រោយមានការអស្ចារ្យនេះកើតឡើងរួចហើយ ទើបធ្វើឱ្យពួកគេដឹងថា ព្រះជាម្ចាស់ទ្រង់គឺខ្ពង់ខ្ពស់ និងអស្ចារ្យជាងអ្វីទាំងអស់។ ហើយប្រាសាទដែលត្រូវបានសាងសង់ជាមួយគ្នានោះ ត្រូវបានគេហៅថា «ប្រាសាទបាបិល»។



សកម្មភាពទី១ សូមគិតពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ)

ហេតុនេះហើយបានជាគេដាក់ឈ្មោះក្រុងនោះថា “បាបិល”



**សកម្មភាពទី២** សូមកាត់រូបឥដ្ឋនីមួយៗ រួចយកទៅបិទតាមពាក្យដែលដូចគ្នា។

Bonjour

สวัสดีครับ | Hello

Ciao | 你好 | Hola

مرحبًا. | Salve | 안녕 | こんにちは

- - - - - - - - - - - - - - - - - - - - - - - - - - - - - -

Hello | 你好 | 안녕 | สวัสดีครับ | Salve

Hola | Ciao | こんにちは | Bonjour | مرحبًا.